សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាំម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
១៨ មិនា ២០១៥

- **សូមគោរព លោកជំទាវ ម៉ុម ថានី អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **សូមគោរព ឯកឧត្តម រស់ ឆាយ អភិបាលរងខេត្តស្វាយរៀង**
- **សូមគោរព លោក ថាច់ រតនា ប្រធានមន្ទីរកសិកម្ម ខេត្តស្វាយរៀង**
- **សូមគោរព លោក យស់ សារ៉ាត ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង**
- **សូមគោរព លោក សៅ ស៊ីថា នាយកសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួនបីជូនដល់ខេត្តស្វាយរៀងរួមមាន "គម្រោងសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មត្នោត ខេត្តស្វាយរៀង" "គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាព្រៃម្នាស់ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង" និង"គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នងនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង"។

គម្រោងទាំងនេះ ដែលយើងតែបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលដៅដើម្បីកែលម្អវិស័យកសិកម្ម និងបរិស្ថាននៃការអប់រំសម្រាប់ប្រជាជននៅក្នុងគម្រោងនិមួយៗ។ ខ្ញុំសង្ឃឹមថា ការកែលម្អវិស័យកសិកម្ម និងវិស័យអប់រំទាំងនេះ គឺជាគន្លឹះសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត។ វិស័យទាំងពីរនេះ គឺជាវិស័យអាទិភាពក្នុងបណ្តាវិស័យដទៃទៀត សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា សម្រាប់ជំនួយឥតសំណងរបស់ជប៉ុនផ្តល់ជូនចំពោះប្រទេសកម្ពុជាផងដែរ។ ជាការពិត ជប៉ុនបាននឹងកំពុងគាំទ្រដល់ការអភិវឌ្ឍប្រទេសកម្ពុជានៅក្នុងវិស័យទាំងនេះអស់រយៈពេលជាងពីរទសវត្សរ៍មកហើយ តាមរយៈការផ្ទេរនូវបច្ចេកវិទ្យានៃការដាំដុះ ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ ការសាងសង់សាលារៀន និងការផ្តល់នូវវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនជាដើម។

គម្រោងទីមួយ មានថវិកាសរុប១០២,២៨៥ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់មន្ទីរកសិកម្មខេត្តស្វាយរៀងសម្រាប់ការសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មត្នោត នៅក្នុងស្រុកកំពង់រោទិ៍។ ជាមួយនិងគម្រោងនេះ នឹងផ្តល់នូវមជ្ឈមណ្ឌលសហគមន៍កសិកម្មមួយដែលមាន រោង និងម៉ាស៊ីនកិនស្រូវចំនួនមួយគ្រឿង ឃ្លាំងសម្រាប់ដាក់អង្ករ រោងយាម រោងសម្រាប់ដាក់អង្កាម និងកន្លែងសម្រាប់ផលិតជីធម្មជាតិ ហើយកសិករប្រមាណជា ៥៥០០នាក់ នឹងទទួលបាននូវជីវភាពរស់នៅកាន់តែប្រសើរឡើង តាមរយៈការលក់អង្ករទៅឲ្យសហគមន៍កសិកម្មក្នុងតម្លៃមួយសមរម្យ។

គម្រោងទីពីរ មានថវិកាសរុប ៧៦,៦០៦ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង សម្រាប់ការសាងសង់អគារសិក្សាមួយខ្នង ជាមួយនិងបង្គន់អនាម័យ ព្រមទាំងការបំពាក់ទៅដោយបរិក្ខារសិក្សានានា នៅសាលាបឋមសិក្សាព្រៃម្នាស់ ក្នុងស្រុកកំពង់រោទិ៍។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងផ្តល់នូវបរិស្ថាននៃការអប់រំ ប្រកបទៅដោយសុវត្ថិភាពនិងមានផាសុខភាពដល់សិស្សានុសិស្សប្រមាណជា៤៥០នាក់ ដែលកំពុងរៀនក្នុងអគារសិក្សាដែលមានលក្ខណៈទ្រុឌទ្រោមទាំងនោះ។

គម្រោងទីបី មានថវិកាសរុប ៨៧,៩៤៩ដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដល់សាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង សម្រាប់ការសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសាលារៀន ព្រមទាំងបង្គន់អនាម័យនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀង។ គម្រោងនេះត្រូវបានរំពឹងថាគរុសិស្សប្រមាណ១២០នាក់ នឹងទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ ដែលនឹងក្លាយជាគ្រូបង្រៀននៅសាលាបឋមសិក្សា បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល។ ខ្ញុំបានដឹងថា អ្នកស្ម័គ្រចិត្តជនជាតិជប៉ុនមួយរូប មកពីអង្គការ CIESF បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងគ្រូបង្រៀនដល់គរុសិស្សនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្វាយរៀងនេះ។

ការងារសាងសង់សម្រាប់គម្រោងទាំងនេះ នឹងចាប់ផ្តើមនាពេលឆាប់ៗនេះ ហើយរំពឹងថានឹងបញ្ចប់ក្នុងរយៈពេលមួយឆ្នាំ។ បើទោះបីជាមានបញ្ហាលំបាកខ្លះៗក្នុងការបន្តការងារនៅរដូវវស្សាយ៉ាងណាក៏ដោយ ក៏ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងទាំងនេះ នឹងត្រូវបានអនុវត្តទៅដោយមិនមានការពន្យាពេល។ នៅក្នុងខែមេសាខាងមុខនេះ ស្ពានត្សឹបាសា នឹងត្រូវបានដាក់អោយដំណើរការជាផ្លូវការ ហើយរំពឹងថានឹងមានការកើនឡើងនូវលំហូរប្រជាជន និងផលិតផលនានាជាច្រើន។ ខ្ញុំសង្ឃឹមថា ស្ពាននេះ រួមជាមួយនិងគម្រោងទាំងបីនេះ នឹងនាំមកនូវការអភិវឌ្ឍបន្ថែមទៀតក្នុងខេត្តស្វាយរៀង ព្រមទាំងជួយដល់សុខមាលភាពដែលជាអាទិភាពសម្រាប់ប្រជាជនរស់នៅទីនោះផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សំណង់ដែលត្រូវបានសាងសង់ដោយគម្រោងទាំងនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវអោយបានយូរអង្វែង ដើម្បីអោយប្រជាជនកាន់តែច្រើន អាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅបាន។ ខ្ញុំសង្ឃឹមថាគម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!